ព្រះរាជាណាចក្រ កម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន ហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី

## និង

## តំណាងប្រតិភូបុគ្គលិក

## ក្រុមហ៊ុន ហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃមួយខែកក្កដា ថ្ងៃទីម្ភៃបី វេលាម៉ោងប្រាំពីនិងសាមសិបនាទីព្រឹក នៅក្រុមហ៊ុនហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី មានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក ប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានធ្វើបច្ចុប្បន្នភាពអំពីស្ថានភាពរបស់ក្រុមហ៊ុនដែលនឹងកំពុងតែជួបប្រទះជូនដល់បុគ្គលិកទាំងអស់ថាលំហូរសាច់ប្រាក់និងការព្យាករណ៍ការចំណាយនានានៅតែជាបញ្ហាប្រឈមសម្រាប់ក្រុមហ៊ុនក្នុងស្ថានភាពបច្ចុប្បន្នព្រោះវិបត្តិនៃការរីករាលដាលជាសាកលនៃជម្ងឺកូវីដ-១៩ និងថ្មីៗនេះព្រឹត្តិការណ៍សហគមន៍ ថ្ងៃ២០កុម្ភៈ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការងារប្រតិបត្តិការចម្ការឈើ ផែនការប្រើប្រាស់ទុនវិនិយោគរបស់ក្រុមហ៊ុនយើងខ្ញុំ។ ដូច្នេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់បុគ្គលិកចំនួន៣នាក់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃ ០១ សីហា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២១។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូន កម្មករនិយោជិតចំនួន ៤០% នៃប្រាក់ខែគោល(គិតជាដុល្លារអាមេរិក)ក្នុង១ខែ សម្រាប់ និយោជិតម្នាក់ៗ ដោយបើកពីរដងក្នុងមួយខែ។ ករណីដែលក្រុមហ៊ុនមានការងារចាំបាច់ណាមួយដែលតម្រូវអោយបុគ្គលិកមកធ្វើការ ក្រុមហ៊ុននឹងបើកប្រាក់ឈ្នួលគិតតាមថ្ងៃដែលនិយោជិតបានមកធ្វើការ។

អង្គប្រជុំបានចប់វេលាម៉ោងប្រាំបីព្រឹក នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

ដើម្បីបង្ហាញពីកិច្ចព្រមព្រៀងប្រជុំខាងលើ យើងខ្ញុំទាំងអស់គ្នាសូមផ្តិតមេដៃ ធ្វើជាសាក្សី ។

ស្នាមមេដៃតំណាងប្រតិភូបុគ្គលិក

លោក ហែម ឈន លោក ខៀវ បាន

កំពង់ស្ពឺ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២១

**ហត្ថលេខាប្រធានប្រតិបត្តិ**

GRANDIS TIMBER LTD.

ហុង លីណា